**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## វឌ្ឍនភាពនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ គិតត្រឹមថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន ឱ្យបានជ្រាបថា ដើម្បីបន្តសម្របសម្រួលដោះស្រាយបញ្ចប់វិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ ក្រសួងបានអញ្ជើញតំណាងភាគីកម្មករនិយោជិត និងតំណាងភាគីនិយោជក មកបន្តប្រជុំដោះស្រាយវិវាទនៅទីស្តីការក្រសួង នៅរសៀលថ្ងៃព្រហស្បតិ៍ ទី១៧ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ២:៣០រសៀល។

ជាក់ស្តែង នៅរសៀលថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ នេះ តំណាងភាគីនិយោជកបានមកចូលរួមប្រជុំតាមការអញ្ជើញរបស់ក្រសួង ប៉ុន្តែគួរឱ្យសោកស្តាយដែលតំណាងភាគីកម្មករនិយោជិតនៅតែបន្តមិនបានមកចូលរួមប្រជុំតាមការអញ្ជើញរបស់ក្រសួងឡើយ ទោះបីជាក្រសួងបានពន្យល់អំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងក្នុងការសម្របសម្រួលដោះស្រាយវិវាទនេះ ជាពិសេសផ្តល់កិច្ចអន្តរាគមន៍តាមផ្លូវច្បាប់ ដើម្បីឱ្យអតីតបុគ្គលិក ៣នាក់ ផ្សេងទៀតបាននៅក្រៅឃុំជាបណ្តោះអាសន្នយ៉ាងណាក៏ដោយ។

សាជាថ្មីម្តងទៀត ក្រសួងក៏សូមអំពាវនាវដល់តំណាងភាគីកម្មករនិយោជិត មេត្តាចូលរួមប្រជុំដោះស្រាយនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ២:៣០រសៀល នៅទីស្តីការក្រសួង និងសូមអនុវត្តតាមការសន្យារបស់ខ្លួន ដែលស្នើសុំកិច្ចអន្តរាគមន៍ឱ្យខ្លួនបាននៅក្រៅឃុំជាបណ្តោះអាសន្ន ដើម្បីធ្វើជាតំណាងអតីតបុគ្គលិកក្នុងការដោះស្រាយវិវាទការងារជាមួយក្រុមហ៊ុន ដោយមិនគួរលើកហេតុផលផ្សេងៗខុសពីការសន្យា ឬស្មារតីនៃកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ចប់វិវាទការងារនេះឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជ្រាបតាមការគួរ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៩